# តើយើងត្រូវយល់ ហើយជឿយ៉ាងដូចម្ដេច
# ដើម្បីទទួលសេចក្ដីសង្គ្រោះពីព្រះយេស៊ូវបាន?

## ក. យើងត្រូវយល់ថា តើព្រះជានរណា?

**១. ព្រះដែលពិតប្រាកដមានតែមួយប៉ុណ្ណោះ គឺជាព្រះដែលបានបង្កើតពិភពលោកទាំងមូល**

*គម្ពីរអេសាយ ៤៥:២២ អស់ទាំងមនុស្សនៅចុងផែនដីអើយ ចូរមើលមកអញ ហើយទទួលសេចក្ដីសង្គ្រោះចុះ ដ្បិតអញនេះជាព្រះ ឥតមាននរណាទៀតឡើយ*

**២. ព្រះបានបង្កើតមនុស្សយើងមក យើងទាំងអស់គ្នាជាកម្មសិទ្ធិរបស់ព្រះអង្គ យើងគួរតែស្រឡាញ់ គោរពថ្វាយបង្គំ ហើយបំរើទ្រង់តែ១ប៉ុណ្ណោះ**

*គម្ពីរ១កូរិនថូស ៨:៦ មានព្រះតែ១ប៉ុណ្ណោះ គឺជាព្រះវរបិតា ដែលរបស់សព្វសារពើកើតមកពីទ្រង់ ហើយយើងរាល់គ្នាក៏សំរាប់ទ្រង់ ក៏មានព្រះអម្ចាស់តែ១ គឺជាព្រះយេស៊ូវគ្រីស្ទ ដែលរបស់សព្វសារពើកើតមកដោយសារទ្រង់ ហើយយើងក៏ដោយសារទ្រង់ដែរ*

**៣. ព្រះល្អបរិសុទ្ធ និងយុត្តិធម៌ ទ្រង់នឹងជំនុំជំរះគ្រប់ទាំងអំពើបាប និងការបះបោរប្រឆាំងនឹងព្រះ ពីព្រោះអំពើបាបត្រូវតែសង**

*គម្ពីរ១យ៉ូហាន ១:៥ នេះជាដំណឹង ដែលយើងខ្ញុំបានឮពីទ្រង់ ហើយក៏ប្រាប់មកអ្នករាល់គ្នា គឺថា ព្រះទ្រង់ជាពន្លឺភ្លឺ គ្មានសេចក្ដីងងឹតណា នៅក្នុងទ្រង់សោះ*

*គម្ពីរសាស្ដា ១២:១៣-១៤ ចូរកោតខ្លាចដល់ព្រះ ហើយកាន់តាមបញ្ញត្តទ្រង់ចុះ ដ្បិតប៉ុណ្ណោះឯងជាកិច្ចទាំងមូលដែលមនុស្សត្រូវធ្វើ ពីព្រោះព្រះទ្រង់នឹងនាំគ្រប់ការទាំងអស់មកដើម្បីជំនុំជំរះ ព្រមទាំងអ្វីៗដែលលាក់កំបាំងផង ទោះល្អឬអាក្រក់ក្តី។:៙៚*

## ខ. យើងត្រូវយល់ថា តើមនុស្សទាំងអស់ជានរណា?

**៤. មនុស្សទាំងអស់ជាអ្នកមានបាប ជាអ្នកបះបោរប្រឆាំងនឹងព្រះ ដោយមិនបានគោរព ហើយមិនបានស្វែងរកព្រះដ៏ពិត**

*គម្ពីររ៉ូម ៣:១០-១២ ដូចមានសេចក្ដីចែងទុកមកថា គ្មានអ្នកណាសុចរិតសោះ សូម្បីតែម្នាក់ ក៏គ្មានផង គ្មានអ្នកណាដែលយល់ គ្មានអ្នកណាដែលស្វែងរកព្រះ គ្រប់គ្នាបាន*

*បែរចេញ ហើយត្រឡប់ជាឥតប្រយោជន៍ទាំងអស់គ្នា គ្មានអ្នកណាដែលប្រព្រឹត្តតាមសេចក្តីសប្បុរសសោះ តែម្នាក់ក៏គ្មានផង*

៥. **ឈ្នួលរបស់បាប គឺសេចក្តីស្លាប់ ហើយការដាច់ចេញពីព្រះអស់កល្បជានិច្ច**

*គម្ពីរ<u>វិវរណៈ ២១:៨</u> តែត្រង់ពួកខ្លាច ពួកមិនជឿ ពួកគួរខ្ពើម ពួកកាប់សំឡាប់គេ ពួកកំផិត ពួកមន្តអាគម ពួកថ្វាយបង្គំរូបព្រះ ហើយគ្រប់ទាំងមនុស្សកំភូត គេនឹងមានចំណែកនៅក្នុងបឹង ដែលឆេះជាភ្លើងនិងស្ពាន់ធ័រ គឺជាសេចក្តីស្លាប់ទី២វិញ*

*គម្ពីរ<u>រ៉ូម ៦:២៣</u> ដ្បិតឈ្នួលរបស់អំពើបាប នោះជាសេចក្តីស្លាប់*

## គ. យើងត្រូវយល់ថា តើព្រះយេស៊ូវជានរណា?

៦. **ទោះបីជាមនុស្សយើងជាអ្នកមានទោសធ្ងន់ក៏ដោយ ព្រះនៅតែស្រឡាញ់មនុស្សលោក ហើយបានយាងមកពីឋានសួគ៌ យកនិស័យជាមនុស្ស ដើម្បីសង្គ្រោះមនុស្សយើងឲ្យរួចផុតពីផលបាប**

*គម្ពីរ<u>រ៉ូម ៦:២៣</u> ដ្បិតឈ្នួលរបស់អំពើបាប នោះជាសេចក្តីស្លាប់ តែអំណោយទាននៃព្រះវិញ គឺជាជីវិតដ៏នៅអស់កល្បជានិច្ច ដោយព្រះគ្រីស្ទយេស៊ូវ ជាព្រះអម្ចាស់នៃយើងរាល់គ្នា។*

*គម្ពីរ<u>រ៉ូម ៥:៨</u> តែឯព្រះ ទ្រង់សំដែងសេចក្តីស្រឡាញ់របស់ទ្រង់ ដល់យើងរាល់គ្នាឲ្យឃើញច្បាស់ដោយព្រះគ្រីស្ទបានសុគតជំនួសយើងរាល់គ្នា នោះគឺក្នុងកាលដែលយើងនៅមានបាបនៅឡើយផង*

៧. **ព្រះយេស៊ូវបានសងថ្លៃលោះបាបរបស់មនុស្សយើង ដោយទ្រង់បានសុគតនៅលើឈើឆ្កាង**

*គម្ពីរ<u>១ពេត្រុស ២:២៤</u> ទ្រង់បានផ្ទុកអំពើបាបរបស់យើងរាល់គ្នា នៅលើរូបអង្គទ្រង់ជាប់លើឈើឆ្កាង ដើម្បីឲ្យយើងបានរស់ខាងឯសេចក្តីសុចរិត ដោយបានស្លាប់ខាងឯអំពើបាបហើយ គឺដោយស្នាមជាំរបស់ទ្រង់ ដែលអ្នករាល់គ្នាបានជា*

៨. **ព្រះយេស៊ូវមានព្រះជន្មរស់ឡើងវិញ ហើយមានជ័យជំនះលើសេចក្តីស្លាប់**

*គម្ពីរ<u>រ៉ូម ១:៤</u> តែខាងឯព្រះវិញ្ញាណនៃសេចក្តីបរិសុទ្ធ នោះបានសំដែងមកច្បាស់ថា*

*ទ្រង់ជាព្រះរាជបុត្រារបស់ព្រះពិត ទាំងមានព្រះចេស្តាផង ដោយទ្រង់បានរស់ពីស្លាប់ឡើងវិញ គឺជាព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់នៃយើងរាល់គ្នា*

## ឃ. យើងត្រូវយល់ថា តើដំណឹងល្អគឺជាអ្វី?

**៩. អស់អ្នកណាដែលកែប្រែចិត្ត ហើយទទួលជឿព្រះយេស៊ូវ អ្នកនោះនឹងបានសង្គ្រោះ**

*គម្ពីរ១ថែស្សាឡូនីច ១:៩-១០ ទាំងបែរចេញពីរូបព្រះ មកឯព្រះដ៏ពិត ឲ្យបានគោរពប្រតិបត្តិដល់ព្រះ ដ៏មានព្រះជន្មរស់នៅនោះវិញ ហើយឲ្យបានចាំព្រះរាជបុត្រាព្រះទ្រង់យាងមកពីស្ថានសួគ៌ ដែលព្រះបានប្រោសឲ្យទ្រង់រស់ពីស្លាប់ឡើងវិញ គឺជាព្រះយេស៊ូវ ដែលទ្រង់ប្រោសឲ្យយើងរួចពីសេចក្តីខ្ញាល់ទៅមុខ*

**១០. ព្រះបានសន្យាថា ទ្រង់នឹងអត់ទោសបាបឲ្យអ្នកជឿ ហើយប្រទានពរពួកគេឲ្យបានចំណែកក្នុងមរតករបស់ព្រះដែលថិតថេរអស់កល្បជានិច្ច**

*គម្ពីរកិច្ចការ ២៦:១៨ ប្រយោជន៍នឹងបំភ្លឺភ្នែកគេ ឲ្យបានបែរចេញពីសេចក្តីងងឹត មកឯពន្លឺ ហើយពីអំណាចអារក្សសាតាំង មកឯព្រះវិញ ដើម្បីឲ្យគេបានរួចពីបាប ហើយបានទទួលមរតកជាមួយនឹងពួកអ្នកដែលបានញែកជាបរិសុទ្ធ ដោយសារសេចក្តីជំនឿជឿដល់ខ្ញុំ*